ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

## សូមគោរពជូន
## ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

*ជាទីគោរពដ៏ខ្ពង់ខ្ពស់!*

**កម្មវត្ថុ៖** របាយការណ៍ ស្តីពីជំនួបទ្វេភាគីរវាងគណៈប្រតិភូកម្ពុជា និងគណៈប្រតិភូសហរដ្ឋអាមេរិកប្រឆាំងការជួញដូរមនុស្ស នារសៀលថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៣។

**យោង៖** - កំណត់ទូតលេខ០៦៧៨/២០២៣ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២៣ របស់ស្ថានទូតសហរដ្ឋអាមេរិកប្រចាំព្រះរាជាណាចក្រកម្ពុជា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ នាងខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា៖ ជំនួបទ្វេភាគីរវាងគណៈប្រតិភូកម្ពុជា និងប្រតិភូសហរដ្ឋអាមេរិកប្រឆាំងការជួញដូរមនុស្ស នៅទីស្តីការក្រសួងមហាផ្ទៃ នារសៀលថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៣ ប្រព្រឹត្តទៅតាមរបៀបវារៈឯកភាពគ្នា ដែលគណៈប្រតិភូសហរដ្ឋអាមេរិកដឹកនាំដោយឯកឧត្តម Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក និងរូបនាងខ្ញុំដឹកនាំគណៈប្រតិភូកម្ពុជា។

**សមាសភាពគណៈប្រតិភូកម្ពុជាតំណាងពី៖** ក្រសួងមហាផ្ទៃ, ក្រសួងកិច្ចការនារី, ក្រសួងយុត្តិធម៌, ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ, ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា, ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ, អគ្គស្នងការដ្ឋាននគរបាលជាតិ, អគ្គនាយកដ្ឋានអន្តោប្រវេសន៍, អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម, ធនាគារជាតិនៃកម្ពុជា, អគ្គលេខាធិកាដ្ឋាននៃគ.ជ.ប.ជ

**សមាសភាពគណៈប្រតិភូសហរដ្ឋអាមេរិក** ចំនួន១៤រូប៖ 1. Bridgette Walker DCM 2. Kerry Pelzman USAID Mission Director, 3. Tom White USAID Director of Democracy and Governance 4. Chris Kelly USAID Acting Deputy Mission Director 5. Moses An, Acting Political and Economic Chief 6. Andrew Leyva, Political Unit Chief, 7. John

Milicevich, Political Officer 8. Amy Shuman, Legal Attach 9. Aven Downie, Acting RSO 10. Gary Narkevich, Homeland Security Assistant Attached, 11. Chanpanhara Oum, Political Specialist ( Interpreter ), 12. Wesley Holzer, Press Officer និង 13. Srey Sokmeth, an interpreter ( backup ) ។

**របៀបវារៈឯកភាពគ្នានៃជំនួបទ្វេភាគី**

**១.ចំណាប់អារម្មណ៍បើក**

**ប្រធានគណៈប្រតិភូសហរដ្ឋអាមេរិក**

- **ឯកឧត្តម Parick Murphy** ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា មានប្រសាសន៍ថ្លែងកោតសរសើរការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កន្លងមក។ **ឯកឧត្តមឯកអគ្គរដ្ឋទូត** ថ្លែងបញ្ជាក់ថា អំពើជួញដូរមនុស្សគឺជាវិបត្តិសកលដែលទាមទារឱ្យបណ្តាប្រទេសទាំងអស់យកចិត្តទុកដាក់ខ្ពស់ ដើម្បីការពារសិទ្ធិ កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។ ទន្ទឹមនេះ **ឯកឧត្តមឯកអគ្គរដ្ឋទូត** បង្ហាញក្តីព្រួយបារម្ភការកើនឡើងនូវការឆបោកតាមប្រព័ន្ធអនឡាញ ដែលកំពុងរីករាលដាលយ៉ាងលឿននៅក្នុងតំបន់ និងសកលលោក ដែលត្រូវមានដំណោះស្រាយឱ្យបានសមស្រប។ ប៉ុន្តែ **ឯកឧត្តមឯកអគ្គរដ្ឋទូត** បញ្ជាក់ជាថ្មីថា គ្មានប្រទេសណាមួយនៅស្ងៀមស្ងាត់ចំពោះអំពើជួញដូរមនុស្សទេ។ ជាមួយគ្នានេះ **ឯកឧត្តមឯកអគ្គរដ្ឋទូត** ថ្លែងថា ភាគីសហរដ្ឋអាមេរិកបាននិងកំពុងពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការអភិវឌ្ឍសមត្ថភាពមន្ត្រីអនុវត្តច្បាប់កម្ពុជាផងដែរ។ គណៈប្រតិភូសហរដ្ឋអាមេរិកនឹងផ្លាស់ប្តូរបទពិសោធន៍ល្អៗគ្នាទៅវិញទៅមកជាមួយគណៈប្រតិភូកម្ពុជា ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

**ប្រធានគណៈប្រតិភូកម្ពុជា**

- **លោកជំទាវកិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងជាអនុប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានថ្លែងនូវការប្តេជ្ញាចិត្តនិងការទទួលខុសត្រូវខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជាអាណត្តិមុនៗក្រោមភាពជាអ្នកដឹកនាំរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី និងបន្តប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលអាណត្តិទី៧ នៃរដ្ឋសភា ក្រោមភាពជាអ្នកដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** និង**ឯកឧត្តម អភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដែលជាឧក្រិដ្ឋកម្មមានអង្គការចាត់តាំង និងជាបញ្ហារួមរបស់បណ្តាប្រទេសទាំងអស់ដែលត្រូវទទួលខុសត្រូវរួមគ្នា។ **លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី** ថ្លែងបញ្ជាក់ផងថា ក្នុងវិបត្តិសកល

នៃជំងឺកូវីដ១៩ ក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងបានប្រើប្រាស់មធ្យោបាយបែបទំនើបតាមប្រព័ន្ធបច្ចេកវិទ្យាដែលជួយសម្រួលដល់ប្រតិបត្តិការជួញដូរមនុស្ស និងកំពុងរីករាលដាលនៅក្នុងតំបន់ និងសកល។ **លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី** បញ្ជាក់ផងដែរថា ភាគីកម្ពុជាត្រៀមខ្លួនរួចរាល់និងរីករាយសហការជាមួយប្រទេសជិតខាង បណ្ដាប្រទេសទាំងអស់ និងភាគីសហរដ្ឋអាមេរិកផងដែរ ព្រមទាំងអង្គការដៃគូអភិវឌ្ឍន៍ជាតិនិងអន្តរជាតិពាក់ព័ន្ធ ដើម្បីឆ្លើយតបបញ្ហារួមគ្នា។ ជាមួយគ្នានេះដែរ **លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី** ថ្លែងថា ភាគីកម្ពុជានឹងសិក្សារៀនសូត្រនូវមធ្យោបាយបែបនវានុវត្តន៍ និងបទពិសោធន៍ល្អៗនៅក្នុងតំបន់ និងសកល ពីភាគីសហរដ្ឋអាមេរិកក្នុងបេសកកម្មប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់។

## ២.ករណីសង្គ្រោះជនជាតិហ្វីលីពីន២៧នាក់

- ឯកឧត្តម **ស៊ាង ជារិទ្ធ** អនុប្រធាននាយកដ្ឋានកណ្ដាលសន្តិសុខ បានបង្ហាញពីប្រតិបត្តិការបង្ក្រាប ការដឹកជញ្ជូនជនជាតិហ្វីលីពីនចំនួន២៧នាក់ពីខេត្តឧត្តរមានជ័យឆ្ពោះទៅគោលដៅនៅខេត្តកោះកុង។ ក្នុងដំណាក់កាលទទួលបានព័ត៌មានពីនគរបាលអមស្ថានទូតនៃប្រទេសអូស្ត្រាលីនៅរាជធានីភ្នំពេញ កាលពីថ្ងៃ២៦ ខែកញ្ញា ឆ្នាំ២០២៣។ ជនល្មើសបានប្រើប្រាស់កម្មវិធីតេឡេក្រាមផ្សព្វផ្សាយព័ត៌មានឱកាសការងារសម្រាប់ជ្រើសរើសជនរងគ្រោះ។ នាយកដ្ឋានកណ្ដាលសន្តិសុខបានដឹកនាំសហការជាមួយនាយកដ្ឋានចារកម្ម នាយកដ្ឋាននគរបាលចរាចរណ៍ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន នាយកដ្ឋានប្រឆាំងបទល្មើសល្បែងពាណិជ្ជកម្ម និងនគរបាលនៅមូលដ្ឋាន ដើម្បីធ្វើប្រតិបត្តិការបង្ក្រាបការដឹកជញ្ជូនជនជាតិហ្វីលីពីន២៧នាក់ពីខេត្តឧត្តរមានជ័យទៅខេត្តកោះកុងដែលសង្ស័យពាក់ព័ន្ធនឹងការជួញដូរមនុស្ស។ ដើម្បីបញ្ឈប់ការដឹកជញ្ជូន ក្រុមការងារចម្រុះបានប្រើវិធានការចរាចរណ៍ក្នុងគោលបំណងឃាត់ដំណើរនិងសួរនាំអ្នកធ្វើដំណើរក្នុងរថយន្តក្រុងទាំងអស់។ មន្ត្រីនគរបាលយុត្តិធម៌ជំនាញប្រឆាំងការជួញដូរមនុស្សបានកំណត់អត្តសញ្ញាណជនជាតិហ្វីលីពីទាំងអស់ រកឃើញថា ជនជាតិហ្វីលីពីនទាំង២៧នាក់ជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលមានសូចនាករៈ ជ្រើសរើសដោយមិនស្របច្បាប់ ដោយសន្យាធបោកឱ្យប្រាក់ខែខ្ពស់ និងគ្មានឯកសារការងារត្រឹមត្រូវ ឯកសារធ្វើដំណើរកាន់កាប់ដោយជនល្មើស ការដឹកជញ្ជូន រយៈពេលធ្វើការ១៦ទៅ១៧ម៉ោង បិទសិទ្ធិសេរីភាពមិនឱ្យចេញពីកន្លែងធ្វើការនិងមិនឱ្យប្រើប្រាស់ទូរស័ព្ទ ជាដើម។ នាយកដ្ឋានកណ្ដាលសន្តិសុខបានបញ្ជូនជនរងគ្រោះជនជាតិហ្វីលីពីនទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីផ្ដល់កិច្ចការពារសុវត្ថិភាព និងសេវាសង្គមសមស្រប។ សាលាដំបូងរាជធានីភ្នំពេញបានចេញដីកា

ឃុំខ្លួនបណ្តោះអាសន្នជនល្មើសជួញដូរមនុស្សក្រោមបទចោទអំពើលក់ដូរមនុស្សមានស្ថានទម្ងន់ទោស។ សំណុំរឿងព្រហ្មទណ្ឌកំពុងស្ថិតក្នុងដំណាក់កាលនីតិវិធីថៅក្រមស៊ើបសួរ។

- ឆ្លើយតបនឹងសំនួរពាក់ព័ន្ធនឹងការពង្រីកវិសាលភាពដល់ម្ចាស់អាជីវកម្មរីសត និងមន្ត្រីសមគំនិតបញ្ហាប្រឈមផ្នែកបច្ចេកវិទ្យា និងផលវិបាកនៃការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ៖
- ឯកឧត្តម **ស៊ាង ជារិទ្ធ** អនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខបានបំភ្លឺថា ប្រតិបត្តិការស៊ើបអង្កេតមិនបញ្ឈប់ត្រឹមនេះទេ។ មន្ត្រីនគរបាលយុត្តិធម៌កំពុងស៊ើបអង្កេតតម្រុយបទល្មើសសម្អាតប្រាក់និងមុខសញ្ញាពាក់ព័ន្ធផ្សេងទៀត។ ឯកឧត្តម **ស៊ាង ជារិទ្ធ** គូសបញ្ជាក់ផងដែរថា ចំណុចរៀនសូត្រគួរឱ្យយកចិត្តទុកដាក់គឺ ការចែករំលែកព័ត៌មានដែលមានគុណភាពពីភាគីពាក់ព័ន្ធ។
- ឯកឧត្តម **ស៊ាង ជារិទ្ធ** អនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ បានបង្ហាញពីបញ្ហាប្រឈមពាក់ព័ន្ធនឹងប្រតិបត្តិការបង្ក្រាប ជាពិសេសពាក់ព័ន្ធនឹងបច្ចេកវិទ្យា រួមមាន៖ ជនល្មើសប្រើអត្តសញ្ញាណសម្គាល់ខ្លួនក្លែងក្លាយ ឈ្មោះក្លែងក្លាយ និងប្រើមធ្យោបាយបិតបាំងនិងលុបបំបាត់ភស្តុតាងដោយស្វ័យប្រវត្តិតាមតេឡេក្រាម ប្រើប្រាស់ម៉ាស់បិទបាំងមុខមាត់ក្នុងស្ថានភាពធម្មតាក្រុមឧក្រិដ្ឋជនមិនស្គាល់អត្តសញ្ញាណគ្នាឯង ដែលជាឧបសគ្គដល់ការស្រាវជ្រាវរកបណ្តាញក្រុមឧក្រិដ្ឋកម្មមានការចាត់តាំងទាំងមូល។
- ឯកឧត្តម **កេង សុម៉ារិទ្ធ** រដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ មានប្រសាសន៍ក្នុងលក្ខខណ្ឌ២ **ទី១.** ជនរងគ្រោះបរទេសមានឯកសារអន្តោប្រវេសន៍គ្រប់គ្រាន់ និង**ទី២.** ជនរងគ្រោះបរទេសមានឯកសារអន្តោប្រវេសន៍មិនគ្រប់គ្រាន់។ បើជនរងគ្រោះមានឯកសារអន្តោប្រវេសន៍គ្រប់គ្រាន់ជនរងគ្រោះមានសិទ្ធិសេរីភាពធ្វើមាតុភូមិនិវត្តន៍ទៅប្រទេសខ្លួន និងមានសិទ្ធិសេរីភាពបន្តរស់នៅកម្ពុជា និងចូលរួមនីតិវិធីដោយសេរី គ្មានការបង្ខិតបង្ខំ និងដាក់លក្ខខណ្ឌអ្វីឡើយ ដោយគ្រាន់តែមានការសម្របសម្រួលតម្រូវការចាំបាច់ពីអាជ្ញាធរមានសមត្ថកិច្ច។ បើជនរងគ្រោះមានឯកសារអន្តោប្រវេសន៍មិនគ្រប់គ្រាន់ ប៉ុន្តែមានឆន្ទៈចូលរួមនីតិវិធីតុលាការ អាជ្ញាធរមានសមត្ថកិច្ចនឹងសម្របសម្រួលឯកសារផ្តល់ភាពស្របច្បាប់ចាំបាច់ដល់ជនរងគ្រោះ ដែលអាចរស់នៅនិងធ្វើការនៅកម្ពុជា។ ប៉ុន្តែបើជនរងគ្រោះមានឯកសារអន្តោប្រវេសន៍មិនគ្រប់គ្រាន់ ចង់ធ្វើមាតុភូមិនិវត្តន៍ទៅប្រទេសខ្លួនវិញ អាជ្ញាធរមានសមត្ថកិច្ចនឹងសម្របសម្រួលដល់ការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដោយគ្មានការបង្ខិតបង្ខំ និងគ្មានលក្ខខណ្ឌ។ ការធ្វើមាតុភូនិវត្តន៍ជនរងគ្រោះអាចបង្កឧបសគ្គខ្លះៗដល់ការផ្តល់សក្ខីកម្មនៅនីតិវិធីតុលាការផងដែរ។

## ៣.កិច្ចខិតខំប្រឹងប្រែងរដ្ឋាភិបាល

**លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី**ប្រធានគណៈប្រតិភូកម្ពុជា បានប្រគល់វេទិកានេះជូន លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បង្ហាញនូវកិច្ចខិតខំប្រឹងប្រែងរាជរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធនឹងអនុសាសន៍របស់សហរដ្ឋអាមេរិក តាមរយៈការប្តេជ្ញាចិត្តបន្តៈ

- ស៊ើបអង្កេតឱ្យបានម៉ឺងម៉ាត់រកទីតាំងប្រព្រឹត្តបទល្មើសនិងបង្ក្រាបឧក្រិដ្ឋកម្មជួញដូរមនុស្សឱ្យដល់ឫសគល់នៃបញ្ហានិងសង្គ្រោះជនរងគ្រោះខ្មែរនិងជនបរទេសនៅកម្ពុជានិងផ្តល់កិច្ចការពារសមស្រប។
- ពង្រឹងការអនុវត្តគោលនយោបាយកំណត់អត្តសញ្ញាណជនរងគ្រោះខ្មែរនិងបរទេសឱ្យបានគ្រប់ជ្រុងជ្រោយឱ្យស្របតាមបទដ្ឋានជាតិ និងលិខិតុបករណ៍គតិយុត្តអន្តរជាតិ និងបណ្តុះបណ្តាលជំនាញពាក់ព័ន្ធដល់មន្ត្រីមានសមត្ថកិច្ចទាំងអស់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- កែលម្អបទដ្ឋាននិងនីតិវិធីដើម្បីការពារសិទ្ធិជនរងគ្រោះនិងជនអន្តោប្រវេសន៍ដែលត្រូវបានសង្គ្រោះដោយផ្តោតការយកចិត្តទុកដាក់លើតម្រូវការខុសគ្នា តាមស្ថានភាពនៃយេនឌ័រ ក្នុងដំណាក់កាលនៃការស្នាក់នៅបណ្តោះអាសន្នក្នុងប្រទេសកម្ពុជាឱ្យកាន់តែល្អប្រសើរ។
- បង្កើនលទ្ធភាពផ្តល់សេវាជូនជនរងគ្រោះគ្រប់ប្រភេទ គ្រប់វ័យ មានពិការភាព ដែលមន្ត្រីនគរបាលយុត្តិធម៌បានកំណត់អត្តសញ្ញាណថា ជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងមានផែនការដាក់បញ្ចូលកញ្ចប់ឧបត្ថម្ភជនរងគ្រោះទៅក្នុងប្រព័ន្ធគាំពារសង្គមមានស្រាប់។
- ពង្រឹងកិច្ចសហការ និងការចូលរួមពីអង្គការដៃគូក្នុងការបង្ការទប់ស្កាត់ និងប្រឆាំងការជួញដូរមនុស្ស និងផ្តល់ធាតុចូលសម្រាប់រៀបចំផែនការសកម្មភាពជាតិប្រឆាំងការជួញដូរមនុស្ស។
- ពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីក្នុងតំបន់និងអន្តរជាតិ ក្នុងគោលដៅប្រឆាំងការជួញដូរមនុស្សគ្រប់ទម្រង់ ជាពិសេសជាមួយភាគីថៃ ដើម្បីដោះស្រាយបញ្ហានៅសល់ សម្រួលនីតិវិធី តម្លៃឱ្យបានសមស្រប ពង្រឹងការទទួលខុសត្រូវពីភាគីពាក់ព័ន្ធក្នុងកិច្ចការពារ និងសុវត្ថិភាពពលករក្នុងវដ្តនៃទេសន្តរប្រវេសន៍ ដើម្បីលុបបំបាត់ការកេងប្រវ័ញ្ច ការជួញដូរមនុស្ស អំពើជួញដូរកម្លាំងពលកម្ម និងទម្រង់ផ្សេងទៀតនៃអំពើជួញដូរមនុស្ស។
- កសាងប្រព័ន្ធទិន្នន័យរួមថ្នាក់ជាតិដែលពាក់ព័ន្ធនឹងកិច្ចការពារជនរងគ្រោះ ការបង្ក្រាប ការផ្តន្ទាទោស ដែលប្រកបដោយវិជ្ជាជីវៈ មានភាពជាក់លាក់ និងអាចចែករំលែកជាមួយភាគីពាក់ព័ន្ធ។
- បង្កើនសមត្ថភាពមន្ត្រីជំនាញគ្រប់ផ្នែក ដើម្បីបង្កើនប្រសិទ្ធិភាពការងារប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់។

ឯកឧត្តម **ស៊ាង ជារិទ្ធ** អនុប្រធាននាយកដ្ឋានកណ្ដាលសន្តិសុខ បានបង្ហាញទិន្នន័យប្រតិបត្តិការស្រាវជ្រាវនិងបង្ក្រាបតាមសំណើផ្ទៀងផ្ទាត់ឃើញថាត្រឹមត្រូវមកក្រសួងមហាផ្ទៃៈ ចាប់គិតពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២មកត្រឹមខែវិច្ឆិកា ឆ្នាំ២០២៣ សរុប១២៣១ករណី មានមនុស្សចំនួន៣២២៥នាក់ (ស្រី៣៨៧នាក់) ស្មើ២៧សញ្ជាតិ។ ប្រភពសំណើមកពី សាមីខ្លួនជនរងគ្រោះ នគរបាលអមស្ថានទូត គ្រួសារជនរងគ្រោះនៅប្រទេសសាមី អង្គការមិនមែនរដ្ឋាភិបាល នគរបាលនិងជនបរទេសនៅកម្ពុជា។ មន្ត្រីជំនាញបានបើកការស៊ើបអង្កេតស្រាវជ្រាវបានសរុប១២១៣ករណី ស្មើ៩៧.៧% រកឃើញ៨០២ករណី មានមនុស្ស២១៥៥នាក់ (ស្រី២៦៩នាក់) ស្មើ២៥សញ្ជាតិ។ មន្ត្រីជំនាញនៃនាយកដ្ឋាននគរបាលកណ្ដាលសន្តិសុខបានរកឃើញ២៨ករណីជាករណីជួញដូរមនុស្ស មានជនរងគ្រោះ៦៥នាក់ (ស្រី១១នាក់) ស្មើ១៣សញ្ជាតិ, ក្នុងនោះបង្ក្រាបជាក់ស្ដែងមាន១៦ករណី និងពន្លាតការស៊ើបអង្កេតបទល្មើសសម្អាតប្រាក់។ មន្ត្រីជំនាញនៃនាយកដ្ឋាននគរបាលកណ្ដាលសន្តិសុខសហការជាមួយមន្ត្រីជំនាញនៃនាយកដ្ឋានដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនបង្ក្រាបបាន១៨ករណីជាករណីបង្ក្រាបជាក់ស្ដែង។

**ឯកឧត្តមឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក** បានថ្លែងកោតសរសើររាជរដ្ឋាភិបាលកម្ពុជាម្ដងទៀត ដែលបង្ហាញកិច្ចខិតខំប្រឹងប្រែងប្ដេជ្ញាចិត្តផ្ទាល់ខ្លួនក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានថ្លែងរំលឹកជំនួបទ្វេភាគីជាមួយ **សម្ដេចតេជោ អតីតនាយករដ្ឋមន្ត្រី** ដែលមានប្រសាសន៍ និងទទួលស្គាល់ថា ប្រទេសកម្ពុជាមិនមែននៅតែជាប្រទេសប្រភពនៃអំពើជួញដូរមនុស្ស តទៅទៀតនោះទេ ប៉ុន្តែកម្ពុជាគឺជាប្រទេសគោលដៅ នៃអំពើជួញដូរមនុស្សផងដែរ។ នាពេលថ្មីៗនេះ ក្នុងដំណើរទស្សនកិច្ចតាមបណ្ដាខេត្ត **ឯកឧត្តមឯកអគ្គរដ្ឋទូត**បានបង្ហាញនូវកង្វល់នៃអំពើជួញដូរមនុស្សនៅកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តនានាក៏បានទទួលស្គាល់បញ្ហានេះដែរ។ ជាមួយគ្នានេះ **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានជម្រាបជូនអង្គប្រជុំទាំងមូលឱ្យជ្រាបផងដែរថា ក្នុងជំនួបទ្វេភាគីជាមួយ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣ **សម្ដេចធិបតី** មានប្រសាសន៍ថា បង្ហាញមធ្យោបាយដោះស្រាយបញ្ហាជួញដូរមនុស្ស គឺមានសារៈសំខាន់ជាងចំណាត់ថ្នាក់។ **ឯកឧត្តមឯកអគ្គរដ្ឋទូត** ជម្រាបអង្គប្រជុំទាំងមូលថា ក្នុងរបាយការណ៍ជួញដូរមនុស្សសហរដ្ឋអាមេរិក ឆ្នាំ២០២៣ គឺមានលក្ខណៈឯករាជ្យ មិនមែនបញ្ហានយោបាយ ដោយពន្យល់ថា ប្រទេសសម្ព័ន្ធមិត្តសហរដ្ឋអាមេរិក រួមមានៈ សាធារណរដ្ឋកូរ៉េ ជប៉ុន ញូហ្ស៊ីឡែន ថៃ គឺស្ថិតក្នុងចំណាត់ថ្នាក់លេខ២នៃរបាយការណ៍ប្រឆាំងការជួញដូរមនុស្ស ឆ្នាំ២០២៣។ ប្រសិនបើរបាយការណ៍នេះមានលក្ខណៈនយោបាយវិញ ប្រទេសសម្ព័ន្ធមិត្តសហរដ្ឋអាមេរិក គឺស្ថិតក្នុងចំណាត់ថ្នាក់លេខ១។

**លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី** មានប្រសាសន៍ឆ្លើយតបថា រាជរដ្ឋាភិបាលថ្មីមានឆន្ទៈប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងយុទ្ធសាស្ត្របញ្ចកោណដែលមានស្នូល លើកកម្ពស់ភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ លើកកម្ពស់ប្រសិទ្ធិភាពច្បាប់និងប្រព័ន្ធយុត្តិធម៌ ពង្រឹងអភិបាលកិច្ចក្នុងវិស័យឯកជននិងធុរកិច្ច ពង្រឹងគុណភាពការងារ។ **លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី** រំលឹកជាថ្មីថា ដើម្បីបន្តពង្រឹងកិច្ចសហប្រតិបត្តិការ ភាគីទាំងពីរគប្បីបន្តជួបពិភាក្សាស្វែងយល់គ្នាទៅវិញទៅមក១ដង ឬ ២ដង ក្នុងមួយឆ្នាំ ទាំងក្នុងកម្រិតមន្ត្រីបច្ចេកទេស និងមន្ត្រីនយោបាយ។ **លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី** បញ្ជាក់ជាថ្មីម្តងទៀតថា រាល់កិច្ចខិតខំប្រឹងប្រែងរដ្ឋាភិបាលគឺមានភាពស្មោះត្រង់ក្នុងកិច្ចសហប្រតិបត្តិការជាមួយភាគីសហរដ្ឋអាមេរិក។

## ៤.កិច្ចពិភាក្សាអនុសាសន៍

### អនុសាសន៍ទី២ និងទី៣

**អនុសាសន៍ទី២.** អនុវត្តគោលការណ៍ណែនាំសម្រាប់កំណត់អត្តសញ្ញាណជនរងគ្រោះឱ្យបានពេញលេញ រួមទាំងជនសង្ស័យថារងគ្រោះនៅក្នុងប្រទេស និងនៅបរទេស ព្រមទាំងត្រូវបណ្តុះបណ្តាលមន្ត្រីជួរមុខក្នុងវិស័យពាក់ព័ន្ធទាំងអស់ឱ្យចេះប្រើប្រាស់គោលការណ៍ណែនាំសម្រាប់កំណត់អត្តសញ្ញាណជនរងគ្រោះ។

**អនុសាសន៍ទី៣.** ពិនិត្យរកសូចនាករនៃការជួញដូរមនុស្សលើគ្រប់បុគ្គលដែលស្ថិតក្នុងទីកន្លែងឃុំខ្លួនជនអន្តោប្រវេសន៍ ឬ ទីកន្លែងថែទាំងជនអន្តោប្រវេសន៍ រួមមាន៖ កម្មករបរទេស បុរស ក្មេងប្រុស ក្រុមLGBTQI+ និងជនមានពិការភាព។

**ឯកឧត្តមឯកអគ្គរដ្ឋទូត** មានប្រសាសន៍ថា ភាគីទាំង២ធ្លាប់បានពិភាក្សាច្រើនដងរួចហើយក្នុងជំនួបទ្វេភាគីកន្លងមក។ **ឯកឧត្តមឯកអគ្គរដ្ឋទូត** ជម្រាបជូនភាគីកម្ពុជាឱ្យប្រុងប្រយ័ត្នថា ស្ថានទូតសហរដ្ឋអាមេរិកធ្លាប់ឮព័ត៌មានពីជនអន្តោប្រវេសន៍ជាជនរងគ្រោះមកថា បន្ទាប់ពីមន្ត្រីអនុវត្តច្បាប់ស៊ើបអង្កេតចប់រួចរាល់ មន្ត្រីអនុវត្តច្បាប់បានបញ្ជូនជនអន្តោប្រវេសន៍ជាជនរងគ្រោះទៅទីកន្លែងឃាត់ខ្លួន និងដាក់ពិន័យជនអន្តោប្រវេសន៍ដោយមូលហេតុស្ថានភាពអន្តោប្រវេសន៍ខុសច្បាប់ពួកគេ ដែលនាំឱ្យពួកគេរងគ្រោះជាលើកទី២ បន្ទាប់ពីភាពរងគ្រោះលើកទី១ប្រព្រឹត្តដោយជនល្មើសជួញដូរមនុស្ស។ **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានយកលិខិតតុបករណ៍ប្រឆាំងអំពើជួញដូរមនុស្សត្រឹមកម្រិតតំបន់អាស៊ានមកបញ្ជាក់បន្ថែមថា ប្រសិនបើកំណត់អត្តសញ្ញាណរកឃើញជនរងគ្រោះដោយអំពើជួញដូរមនុស្សរដ្ឋភាគីមិនត្រូវដាក់ទណ្ឌកម្មជនរងគ្រោះដោយមូលហេតុអន្តោប្រវេសន៍ខុសច្បាប់ រួមមានចូលប្រទេសខុសច្បាប់ រស់នៅខុសច្បាប់ និងធ្វើការដោយខុសច្បាប់ ឬ ជនរងគ្រោះបានប្រព្រឹត្តបទល្មើសផ្សេងទៀតដែលបណ្តាលមកពីផលវិបាកដោយផ្ទាល់ពីអំពើជួញដូរមនុស្ស។ ទន្ទឹមនេះ រដ្ឋភាគីត្រូវការពារសិទ្ធិ

របស់ជនអន្តោប្រវេសន៍រងគ្រោះដោយអំពើជួញដូរមនុស្ស ដែលជៀសវាងឱ្យជនរងគ្រោះរងគ្រោះលើកទី២ ដោយសារការអនុវត្តច្បាប់។ **លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី** ប្រគល់វេទិកានេះជូន តំណាងក្រសួងយុត្តិធម៌ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្លើយបំភ្លឺ។

ឯកឧត្តម **កេង សុម៉ារិទ្ធ** រដ្ឋលេខាធិការ នៃក្រសួងយុត្តិធម៌ឆ្លើយបំភ្លឺថា ដើម្បីផ្តល់កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្សឱ្យបានពេញលេញ យើងត្រូវធ្វើការកំណត់អត្តសញ្ញាណរកជនរងគ្រោះ និងជនសង្ស័យជាមុនសិន។ ក្នុងដំណើរការនីតិវិធី មន្ត្រីនគរបាលយុត្តិធម៌មានតួនាទីកំណត់អត្តសញ្ញាណរកជនរងគ្រោះបឋមដែរ រួចព្រះរាជអាជ្ញាក៏មានភារកិច្ចកំណត់អត្តសញ្ញាណរកជនរងគ្រោះ និងជនសង្ស័យក្នុងដំណាក់កាលខ្លួនផងដែរ មុនបញ្ជូនសំណុំរឿងទៅដំណាក់កាលផ្សេងទៀត។ ក្នុងដំណើរការកំណត់អត្តសញ្ញាណ មន្ត្រីជំនាញនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក៏ចូលរួមផងដែរ។ **ឯកឧត្តមរដ្ឋលេខាធិការ** នឹងឆ្លើយបំភ្លឺបន្ថែមទៀតនៅឱកាសជំនួបទ្វេភាគី រវាង Ambassador at Large និងឯកឧត្តម **កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្នុងពេលខាងមុខ។

ឯកឧត្តម **ញ៉ឹក វណ្ណា៉** រដ្ឋលេខាធិការ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានប្រសាសន៍ថា ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា និង**ទីភ្នាក់ងារ JICA** កំពុងអនុវត្តគម្រោងការងារសាកល្បងសម្រាប់កំណត់អត្តសញ្ញាណជនរងគ្រោះ និងអភិវឌ្ឍសមត្ថភាពមន្ត្រីជួរមុខ នៅខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប និងខេត្តត្បូងឃ្មុំ រួចនឹងពង្រីកវិសាលភាពនៃគម្រោងនេះនៅទូទាំង២៥ រាជធានី ខេត្ត។ **ឯកឧត្តមរដ្ឋលេខាធិការ** បញ្ជាក់ផងដែរថា ជនរងគ្រោះខ្មែរនិងបរទេសមានសិទ្ធិទទួលបានកិច្ចការពារដូចគ្នា និងគ្មានការរើសអើង ដោយយកចិត្តទុកដាក់លើគោលការណ៍យេនឌ័រផងដែរ។ បច្ចុប្បន្ន ភាគីថៃបានផ្តល់ជំនួយឥតសំណងសម្រាប់សាងសង់មជ្ឈមណ្ឌលសំចតប៉ោយប៉ែត និងបានសម្ភោធដាក់ឱ្យប្រើប្រាស់ ដើម្បីទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

ឯកឧត្តម **ជីវ ផល្លី អគ្គស្នងការរង** នៃអគ្គស្នងការដ្ឋាននគរបាលជាតិឆ្លើយបំភ្លឺថា ការកំណត់អត្តសញ្ញាណជនរងគ្រោះអាចចែកចេញជា៣ប្រភេទ។ **ទី១.** ប្រសិនបើជនរងគ្រោះទៅស្វែងរកជំនួយពីអង្គការដៃគូ បុគ្គលិកអង្គការដៃគូអាចកំណត់អត្តសញ្ញាណរកភាពរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប រួចបុគ្គលិកអង្គការដៃគូត្រូវបញ្ជូនជនរងគ្រោះទៅជួបមន្ត្រីនគរបាលយុត្តិធម៌ជំនាញប្រឆាំងការជួញដូរមនុស្ស ធ្វើការកំណត់អត្តសញ្ញាណរកភាពរងគ្រោះដោយអំពើជួញដូរមនុស្ស។ ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌រកមិនឃើញភាពរងគ្រោះដោយអំពើជួញដូរមនុស្ស បុគ្គលិកអង្គការដៃគូមិនអាចហៅជននោះ ជាជនរងគ្រោះដោយអំពើជួញដូរមនុស្សបានទេ។ **ទី២.** ប្រសិនបើជនរងគ្រោះទៅស្វែងរកជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ នោះមន្ត្រីនគរបាលយុត្តិធម៌ជំនាញប្រឆាំងអំពើជួញដូរមនុស្សមានភារកិច្ចកំណត់អត្តសញ្ញាណរកភាពរងគ្រោះ និងសហការជាមួយភាគីពាក់ព័ន្ធផ្តល់សេវា

សមស្របជូនជនរងគ្រោះ រួចកសាងសំណុំរឿងបញ្ជូនទៅព្រះរាជអាជ្ញាបន្តនីតិវិធីនៅតុលាការ។ **ទី៣.** ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរមានភារកិច្ចកំណត់រកភាពរងគ្រោះដោយអំពើជួញដូរមនុស្ស។ **ឯកឧត្តមអគ្គស្នងការរង** បន្ថែមថា នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន មានអង្គការដៃគូសហការជាង៣៥ និងរៀបចំកិច្ចប្រជុំជាទៀងទាត់។ កន្លងមក នគរបាលជាតិបាននិងកំពុងសហការយ៉ាងល្អជាមួយ FBI, HIS, RSO, Interpol។ **ឯកឧត្តមអគ្គស្នងការរង** គូសបញ្ជាក់ផងដែរថា មន្ត្រីនគរបាលជំនាញមានវិជ្ជាជីវៈរក្សានូវឧត្តមប្រយោជន៍នៃសិទ្ធិរបស់ជនរងគ្រោះនៅគ្រប់នីតិវិធី។

**៥.ចំណាប់អារម្មណ៍បិទ**

លោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** អនុប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានសេចក្តីសោមនស្សរីករាយដែលគណៈប្រតិភូសហរដ្ឋអាមេរិក បានចំណាយពេលវេលាស្វែងយល់ព័ត៌មានបន្ថែមនូវកិច្ចខិតខំប្រឹងប្រែងប្រឆាំងអំពើជួញដូរមនុស្សពីតំណាងរដ្ឋាភិបាលកម្ពុជា។ **លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី** ស្នើសុំឱ្យរៀបចំក្រុមការងារបច្ចេកទេសជាសេនាធិការជូនមន្ត្រីនយោបាយនៃភាគីទាំង២ ដើម្បីជួបពិភាក្សាគ្នាលម្អិតលើផែនការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៣-២០២៤ និងរៀបចំរបាយការណ៍។

ឯកឧត្តម Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក បានថ្លែងអំណរគុណចំពោះគណៈប្រតិភូកម្ពុជា។ **ឯកឧត្តមឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក** បានឱ្យដឹងថា គណៈប្រតិភូកម្ពុជាអាចមានឱកាសជួបពិភាក្សាបន្ថែមជាមួយ Ambassador at Large ដែលជាប្រធានការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងត្រួតពិនិត្យវាយតម្លៃរបាយការណ៍ សហរដ្ឋអាមេរិក នាពេលខាងមុខ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដោយក្តីអនុគ្រោះដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីនាងខ្ញុំ៕

ថ្ងៃ ខែ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៣

**អនុប្រធានគណៈកម្មាធិការជាតិ**
**ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**